# វឌ្ឍនភាពនៃការឆ្លើយតបទៅនឹងមេរោគអេដស៍/ជំងឺអេដស៍ ឆ្ពោះទៅសម្រេចបានគោលដៅ ៩៥ ៩៥ ៩៥ នៅឆ្នាំ២០២៥ ក្នុងខេត្តកំពង់ចាម នៅត្រីមាសទី៣ ឆ្នាំ២០១៩

រាជធានីភ្នំពេញ  ថ្ងៃពុធ ១០កើត ខែ កត្តិក ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣
ត្រូវនឹងថ្ងៃទី ០៦ ខែ វិច្ឆិកា គ.ស ២០១៩

មន្ទីរសុខាភិបាលខេត្តកំពង់ចាម

# មាតិកា

- ស្ថានភាពទូទៅ
- សមិទ្ធិផលដែលសម្រេចបានរហូតមកដល់ត្រីមាសទី៣ ឆ្នាំ២០១៩
- ការឆ្លើយតបទៅនឹងគោលដៅ 95-95-95 នៅឆ្នាំ២០២៥
- បញ្ហាប្រឈម
- ការងារដែលត្រូវធ្វើបន្ត

# មូលដ្ឋានសុខាភិបាលក្នុងខេត្តកំពង់ចាម

- មន្ទីរសុខាភិបាលខេត្តៈ ១
- ការិយាល័យសុខាភិបាលស្រុកប្រតិបត្តិ: ៩
- មន្ទីរពេទ្យខេត្តៈ ១
- មន្ទីរពេទ្យបង្អែកស្រុកៈ ៨
- មណ្ឌលសុខភាពៈ ៩០

**មានបណ្តាញធ្វើតេស្តឈាមដោយដោះឈាមនៅចុងម្រាមដៃ**

✓ នៅគ្រប់មណ្ឌលសុខភាពក្នុងខេត្ត
✓ នៅមន្ទីរពេទ្យខេត្ត និងមន្ទីរពេទ្យបង្អែកស្រុក
✓ នៅគ្លីនិករ៉ាក់(RHAC)
✓ អង្គការសមាគមនារីកម្ពុជាដើម្បីសន្តិភាពនិងអភិវឌ្ឍន៍(CWPD) ធ្វើតេស្តលើក្រុម នារីបម្រើសេវាកម្សាន្ត នៅក្រុងកំពង់ចាម
✓ អង្គការសុខភាពបុរសនៅកម្ពុជា(MHC) ធ្វើតេស្តលើក្រុមបុរសរួមភេទជាមួយបុរស(MSM),និងក្រុមបុរសប្លែងភេទ(TG)នៅក្រុងកំពង់ចាម

# កន្លែងព្យាបាលនិងថែទាំ(Pre-ART/ART Services) ក្នុងខេត្តកំពង់ចាម




មាន៥កន្លែងក្នុងខេត្តនៅ៖

- មន្ទីរពេទ្យខេត្ត
- មន្ទីរពេទ្យបង្អែក ជើងព្រៃ
- មន្ទីរពេទ្យបង្អែក ចំការលើ
- មន្ទីរពេទ្យបង្អែក ស្រីសន្ធរ
- មន្ទីរពេទ្យបង្អែក បាធាយ

# អង្គការដែគូសំខាន់ៗដែលសហការជាមួយ

| ឈ្មោះ អង្គការ | ធ្វើសកម្មភាព | |
|---|---|---|
| មូលនិធិថែទាំសុខភាពអ្នកជំងឺអេដស៍<br>AIDS Health care Foundation (AHF) | ថែទាំនិងព្យាបាល នៅមន្ទីរពេទ្យខេត្តកំពង់ចាម | |
| សកម្មភាពដើម្បីសុខមាលភាពស្ត្រីកម្ពុជា<br>Kampuchea Woman's Welfare Action (KWWA) | ថែទាំនិងព្យាបាល នៅមន្ទីរពេទ្យខេត្ត, មន្ទីរពេទ្យស្រីសន្ធរ, មន្ទីរពេទ្យជើងព្រៃ, មន្ទីរពេទ្យចំការលើ និងមន្ទីរពេទ្យបាធាយ | |
| សមាគមនារីកម្ពុជាដើម្បីសន្តិភាពនិងអភិវឌ្ឍន៍<br>Cambodia Women for Peace and Development (CWPD) | បង្ការ ទៅលើក្រុមស្ត្រីបម្រើសេវាកម្សាន្ត ក្នុងក្រុងកំពង់ចាម | |
| សុខភាពបុរសកម្ពុជា<br>Men's Health Cambodia (MHC) | បង្ការ ទៅលើក្រុមបុរសស្រឡាញ់បុរស និងបុរសប្លែងភេទ ក្នុងក្រុងកំពង់ចាម និង ចំការលើ | |
| ភ្នំស្រីដើម្បីអភិវឌ្ឍន៍<br>Phnom Srey Organization for Development (PSOD) | បង្ការ ទៅលើក្រុមស្ត្រីចំណាកស្រុក | |
| ស្ពាន<br>Spien | ថែទាំ អ្នកជំងឺអេដស៍ និងកុមារកំព្រា នៅសហគមន៍ | |

# ក្រុមប្រឈមជាបុរស(MSM & TG)

## ផ្តល់ទិន្នន័យដោយអង្គការសុខភាពបុរសនៅកម្ពុជា(MHC) ខេត្តកំពង់ចាម ត្រីមាសទី២ឆ្នាំ២០១៩

| ស្រុកប្រតិបត្តិ | បុរសរួមភេទបុរស MSM | បុរសប្លែងភេទ TG | TOTAL |
|---|---|---|---|
| កំពង់ចាម-កំពង់សៀម | **657**<br>HIV (+): 2<br>Syph(+): 1 | **123**<br>HIV (+): 1<br>Syph(+): 0 | **780**<br>HIV (+): 3<br>Syph(+): 1 |
| ចំការលើ | **204**<br>HIV(+): 0<br>Syph(+): 1 | **56**<br>HIV(+): 0<br>Syph(+): 2 | **260**<br>HIV(+): 0<br>Syph(+): 3 |
| សរុប | **861** | **179** | **1040** |

ប្រភព: MHC- KCM

# ក្រុមប្រឈមជានារីបម្រើសេវាកម្សាន្ត(FEW)

## ចំនួន និងប្រភេទគ្រឹះស្ថានក្នុងតំបន់គ្របដណ្តប់គម្រោងបានចុះបញ្ជីក្នុងត្រីមាសទី៣ ឆ្នាំ២០១៩

ផ្តល់ទិន្នន័យដោយ **សមាគមនារីកម្ពុជាដើម្បីសន្តិភាពនិងអភិវឌ្ឍន៍(CWPD)ខេត្តកំពង់ចាម**

| ល.រ | ស្រុកប្រតិបត្តិ | ប្រភេទសេវា | ចំនួនទីតាំងគ្រឹះស្ថាន | ចំនួនស្ត្រីគោលដៅ |
|---|---|---|---|---|
| 1 | កំពង់ចាម-កំពង់សៀម | ខារ៉ាអូខេ | 15 | 537 |
| 2 | កំពង់ចាម-កំពង់សៀម | ម៉ាស្សា | 17 | 143 |
| 3 | កំពង់ចាម-កំពង់សៀម | ហាងកាហ្វេ | 5 | 14 |
| | **សរុប** | | **37** | **694** |

-រហូតមកដល់ដំណាច់ខែមិថុនាឆ្នាំ២០១៩នេះ មានស្ត្រីបម្រើសេវាកម្សាន្ត១៩នាក់និងដៃគូ១នាក់ មាន HIV(+) បានចុះបញ្ជីព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ ។

-ក្នុងត្រីមាសទី៣ឆ្នាំ២០១៩ បានរកឃើញ អ្នកផ្ទុកមេរោគអេដស៍ ១នាក់ ។

ប្រភព: CWPD-KCM

# សមិទ្ធិផលដែលកម្មវិធីអេដស៍ខេត្តកំពង់ចាម សម្រេចបាន គិតត្រឹមត្រីមាសទី៣ ឆ្នាំ២០១៩

# ការធ្វើតេស្តដោយដោះចុងម្រាមដៃនិងផ្តល់ប្រឹក្សា(HTS)ប្រចាំត្រីមាស






ប្រភព: Data Management KCM

# ស្ត្រីមានផ្ទៃពោះនិងដៃគូដែលបានមកពិនិត្យឈាមដោយជោះចុងម្រាមដៃ

| | ត្រីមាសទី១ | | ត្រីមាសទី២ | | ត្រីមាសទី៣ | | ត្រីមាសទី៤ | | សរុប-២០១៩ | |
|---|---|---|---|---|---|---|---|---|---|---|
| | សរុប | ប្រតិកម្ម | សរុប | ប្រតិកម្ម | សរុប | ប្រតិកម្ម | សរុប | ប្រតិកម្ម | សរុប | ប្រតិកម្ម |
| ស្ត្រីមានផ្ទៃពោះ | 4,333 | 3 | 4,357 | 1 | 4,446 | 2 | | | 13,136 | 6 |
| ដៃគូ | 473 | 0 | 417 | 0 | 511 | 0 | | | 1,401 | 0 |
| សរុប | 4,806 | 3 | 4,774 | 1 | 4,957 | 2 | | | 14,537 | 6 |

# ការធ្វើតេស្តដោយស្ម័គ្រចិត្ត,ផ្តល់ប្រឹក្សានិងរក្សាការសម្ងាត់ប្រចាំត្រីមាស

## (HTS-ART/VCCT)



# អ្នកជំងឺសកម្មដែលទទួលសេវាព្យាបាលប្រចាំត្រីមាស
# Active patients received ART services by Quarter




ប្រភព: Data Management KCM

# អ្នកជំងឺសកម្មនៅត្រីមាសទី៣-២០១៩

| ART Clinic | ស្រី | សរុប | Viral load Suppressed | % VL Suppressed |
|---|---|---|---|---|
| កំពង់ចាម | 1098 | 2076 | 1973 | 95.03% |
| ជើងព្រៃ | 281 | 539 | 511 | 94.80% |
| ស្រីសន្ធរ | 112 | 200 | 169 | 84.50% |
| ចំការលើ | 109 | 189 | 178 | 94.17% |
| បាធាយ | | 01 | | |
| សរុប | | 3005 | 2831 | 94.20% |

# 3-ការឆ្លើយតបទៅនឹងគោលដៅ 95-95-95 នៅឆ្នាំ២០២៥ របស់កម្មវិធីអេដស៍ខេត្តកំពង់ចាម

**និយមន័យ:**

**95 ទី១៖**គឺនៅ២០២៥: ៩៥%នៃអ្នកដែលមានផ្ទុកមេរោគអេដស៍ក្នុងខ្លួនត្រូវបានដឹងអំពីស្ថានភាពខ្លួនឯង

**95 ទី២៖**គឺ៩៥%នៃអ្នក(95 ទី១)ត្រូវបានទទួលការព្យាបាលដោយឱសថប្រឆាំងនឹងមេរោគអេដស៍ ឬហៅថាថ្នាំពន្យារ (ARV)

**95 ទី៣៖**គឺ៩៥%នៃអ្នក(95 ទី២)មានបន្ទុកមេរោគអេដស៍ក្នុងឈាមទាបបំផុតគឺយ៉ាងច្រើនណាស់ក៏មិនដល់១០០០ក្នុង១មីល្លីលីត្រឈាម

# លទ្ធផលឆ្លើយតបគោលដៅ 95-95-95 នៅឆ្នាំ២០២៥
## គិតត្រឹមត្រីមាសទី3ឆ្នាំ២០១៩

| | Estimation in 2019 | Achievement | % |
|---|---|---|---|
| **95 ទី១** | Old: 3528 (95%= 3352) | **3009** | **85.28%** |
| | New: 5388 (95%= 5119) | **3009** | **55.84%** |
| **95 ទី២** | | **3005** | **99.86%** |
| **95 ទី៣** | | **2831** | **94.20%** |

# បញ្ហាដែលកំពុងតែប្រឈម

| បញ្ហា | ដំណោះស្រាយ |
|---|---|
| ➢មិនមានថវិកាជំនួយគ្រប់គ្រាន់សម្រាប់ដំណើរការកម្មវិធី<br><br>➢ការគ្រប់គ្រងទៅលើក្រុមប្រឈមមុខខ្ពស់ (នារីបម្រើសេវាកម្សាន្ត, បុរសស្រឡាញ់បុរស, បុរសប្លែងភេទ) ធ្វើបានតែនៅក្រុងកំពង់ចាម ដោយមិនបានចូលទៅដល់ស្រុកផ្សេងទៀតជាពិសេសតាមបណ្តោយផ្លូវជាតិលេខ៦ និង៧ ដែលជាតំបន់រោងចក្រនិងសម្បូណ៌ទៅដោយសេវាកម្សាន្ត | ➢ធ្វើផែនការស្នើសុំថវិកាជាតិសម្រាប់ដំណើរការជាបន្តទៀត<br><br>➢អំពាវនាវស្វែងរកជំនួយពីអង្គការដៃគូ ដើម្បីជួយទប់ស្កាត់ការចម្លង អេដស៍និងកាមរោគ។ ក្រុមមន្ត្រីរាជការនៅថ្នាក់ខេត្តសហការជាមួយមន្ត្រីមូលដ្ឋាន ឆ្លៀតចុះទៅអប់រំផ្ទាល់ និងស្នើសុំតេស្តដើម្បីស្រាវជ្រាវរកអ្នកមានផ្ទុកHIV ឬ មានកាមរោគ មកព្យាបាល ទប់ស្កាត់ការចម្លង។ |

# បញ្ហាដែលកំពុងតែប្រឈម

| បញ្ហា | ដំណោះស្រាយ |
|---|---|
| ➢ ដាច់សកម្មភាពជាមួយក្រុមចាក់ថ្នាំញៀន (PWID) និងក្រុមប្រើថ្នាំញៀន(PWUD) ដោយសារតែអង្គការដែលធ្លាប់ធ្វើការងារនេះ(BSDA) ចប់គម្រោង។ | ➢ ទំនាក់ទំនងរកអង្គការដៃគូជួយ និងសហការណ៍ជាមួយអាជ្ញាធរ តាមមូលដ្ឋានដើម្បីយកពួកគាត់មកអប់រំ និង ធ្វើ តេស្តរកមេរោគអេដស៍។ |
| ➢ មន្ទីរសម្ភពឯកជនមិនបានធ្វើតេស្តរកមេរោគអេដស៍និងស្វាយដល់ស្រ្តីមានផ្ទៃពោះ និងស្រ្តីមកឆ្លងទន្លេទេ(ដែលនឹងប៉ះពាល់ដល់គោលដៅលុបបំបាត់ការចម្លងមេរោគអេដស៍-ស្វាយ ពីម្តាយទៅកូន(e.MTCT)នៅឆ្នាំ២០២៥)។ | ➢ បានរាយការណ៍ជូនក្រសួងសុខាភិបាលនិងមជ្ឈមណ្ឌលជាតិគាំពារមាតាទារក ខាងលុបបំបាត់ការចម្លងមេរោគអេដស៍-ស្វាយពីម្តាយទៅកូនរួចហើយ តែមិនទាន់ឃើញមានសកម្មភាពឆ្លើយតប។ |

# ការងារដែលត្រូវធ្វើជាបន្ត

- ធ្វើផែនការសកម្មភាពដាក់បញ្ចូលទៅក្នុងផែនការប្រចាំឆ្នាំ(AOP)របស់មន្ទីរសុខាភិបាលខេត្តដើម្បីដំណើរការកម្មវិធីដោយថវិកាជាតិ លើសកម្មភាពខ្លះ។
- បន្តការងារដែលមានស្រាប់ឲ្យមាននិរន្តរភាព
- ខិតខំបង្កើនការងារស្រាវជ្រាវរកអ្នកដែលមានផ្ទុកHIV ទៅតាមលទ្ធភាព
- ពង្រឹងសមត្ថភាពនិងគុណភាពនៃការធ្វើតេស្តឈាម
- ពង្រឹងគុណភាពនៃការផ្តល់សេវា
- ព្យាយាមលុបបំបាត់ភាពរើសអើង មាក់ងាយ លើអ្នកជំងឺអេដស៍
- សហការល្អជាមួយអង្គការដៃគូ ព្រមទាំងអាជ្ញាធរគ្រប់ជាន់ថ្នាក់ទាំងអស់

# សូមអរគុណ